| | |
|---|---|
| **ទុត្ថា**<br>មានរឿងរ៉ាវជាច្រើន.....<br>**ហើយនេះគឺជារឿងរ៉ាវអំពីអំពើឧក្រិតនិងភាពអាម៉ាស់ដែលគ្មានថ្ងៃបញ្ចប់ឡ**<br><br>**ច្រៀងរួមគ្នា :**<br>ការចងចាំ ។<br>ការចងចាំជាច្រើន ។<br>វាចេះតែវិលទៅវិលមក<br>ដូចជាកាំកង់ដែលកំពុងវិលអញ្ចឹង។<br>តែងតែមានលក្ខណៈដូចគ្នាជានិច្ច ។<br>ដូចជាកាំកង់.....កង់វិលនៅក្នុងក្បាលរបស់ខ្ញុំ ។<br><br>យើងទាំងអស់គ្នាកំពុងស្ថិតនៅក្នុងផ្ទះខ្ទមមួយ។<br>ខ្ញុំឃើញលោកវិទ្ធីនិងម្តាយរបស់គាត់ឡពួកគាត់អង្គុយជិតគ្នា ឡ លោកវិទ្ធីមានអាយុ ៥១ឆ្នាំ ។ គាត់បាត់បង់នូវក្តីប្រាថ្នាក្នុងជីវិត ហើយម្តាយរបស់គាត់មានអាយុ ៧៦ឆ្នាំ។ គាត់គឺជាអ្នកការពារកូនរបស់គាត់។<br>សូមអញ្ជើញស្តាប់លោកយាយជាម្តាយ។<br><br>**សុវណ្ណា**<br>យើងរស់នៅក្នុងភាពលំបាកលំបិន ។<br>កូនខ្ញុំមានបញ្ហាក្បាល ។វាចេះតែបោកទង្គិចក្បាលរបស់វា មើលទៅហាក់បីដូចជាក្បាលរបស់វាកំពុងធ្វើ | |

អោយវាឈឺចាប់អញ្ចឹង ។

កូនខ្ញុំមានជម្ងឺហើយជំងឺនេះមានទាក់ទងទៅនឹងការលំបាកវេទនារបស់វាតែម្តង ។កូនខ្ញុំមិនមែនជាមនុស្សអាក្រក់ទេ ។វាមិនធ្លាប់ធ្វើអំពើអាក្រក់ទាល់តែសោះ ។ ប៉ុន្តែកាលថ្ងៃមួយនោះនៅពេលដែលគេចាប់កូនខ្ញុំយកទៅដាក់គុកគឺថ្ងៃនោះហើយដែលបានបំផ្លាញជីវិតយើង

**ធារី**

គេចាប់**គាត់**យកទៅដាក់គុកអ្វើ ?

**សុវណ្ណា**

គេបានចងកូនខ្ញុំ ។

គេចង់បានឈ្មោះ ។

**រិទ្ធី**

ខ្ញុំអត់បានប្រាប់ឈ្មោះនរណាទេ.....

**សុវណ្ណា**

គេវ៉ាយកូនខ្ញុំខ្លាំងណាស់ ។

**ធារី**

ឯងបានប្រាប់ឈ្មោះទៅគេ....

**សុវណ្ណា**

| | |
|---|---|
| គេធ្វើទារុណកម្មកូនខ្ញុំ......<br><br>**រិទ្ធី**<br>ខ្ញុំអោយឈ្មោះមនុស្សពីរនាក់ដល់ពួកវា....<br><br>**ធារី**<br>ឯងបង្ហើបឈ្មោះមនុស្សច្រើនណាស់....<br><br>**សុវណ្ណា**<br>គេដុតដៃ ជើងកូនខ្ញុំ......<br><br>**ធារី**<br>ឯងបញ្ជូនមនុស្សទៅភូមិឆ្អឹងសច្រើនណាស់.....<br><br>**រិទ្ធី**<br>គេចងខ្ញុំព្យួរក្បាលចុះក្រោម<br>ខ្ញុំប្រាប់ឈ្មោះមនុស្ស៥នាក់ដល់ពួកគេ<br>គេជ្រមុជខ្ញុំទៅក្នុងទឹក<br>ខ្ញុំប្រាប់ឈ្មោះមនុស្ស៨នាក់ដល់ពួកគេ<br>គេយកខ្សែតីវ៉ាយខ្ញុំរហូតស្ទើរស្លាប់<br><br>**សុវណ្ណា**<br>កូនខ្ញុំវាយំដូចសត្វអណ្តើកអាំងភ្លើងអញ្ចឹង<br><br>**រិទ្ធី** | <br><br>**ផ្កាកូលាបមួយទងដែលទន់ទោរដោយកំលាំងខ្យល់បក់បោក ហើយញាំមញីដោយបន្ទា តែវានៅតែអាចធ្វើអោយដើមរបស់នៅត្រង់ឡើងលើដដែល។**<br>**រីក៏**<br>**ការចងចាំ ។**<br>**ការចងចាំជាច្រើន ។**<br>**វាចេះតែវិលទៅវិលមក**<br>**ដូចជាកាំកង់ដែលកំពុងវិល**<br>**អញ្ចឹង។តែងតែមានលក្ខណ:**<br>**ដូចគ្នាជានិច្ច។ ដូចជាកាំកង់..**<br>**កង់វិលនៅក្នុងក្បាលរបស់ខ្ញុំ។** |

| | |
|---|---|
| ខ្ញុំនឹកឃើញឈ្មោះអ្នកណា ខ្ញុំក៏ប្រាប់ទៅគេ។<br><br>១០នាក់ ២០នាក់...ខ្ញុំប្រាប់ទាល់តែគេពេញចិត្ត ។<br><br>**ធារី**<br>ឯងប្រាប់ឈ្មោះគេប្រហែលជា ៣០នាក់ ។ បើក្នុងចំណោមនោះពួកគេម្នាក់ៗនិយាយតែឈ្មោះមនុស្ស ៣០ឬក៏៤០នាក់នោះ ក្នុងរយៈ ពេលតែ១ឆ្នាំ ឬ២ឆ្នាំ ប្រាកដជាគ្មានសល់មនុស្សទេ ។<br><br>**សុវណ្ណា**<br>កូនខ្ញុំមិនចង់ធ្វើអញ្ចឹងទេ ។<br>តើនរណាសម្លាប់នរណាទៅ ។ ខ្ញុំមិនដឹងទេ ។<br><br>**រិទ្ធី**<br>ខ្ញុំតែងតែគិតដល់អ្នកដែលត្រូវស្លាប់ជារៀងរាល់ថ្ងៃ ។ ខ្ញុំបន់ព្រះថា បើខ្ញុំហៅឈ្មោះគេសូមព្រះជួយកុំអោយព្រលឹងរបស់គេរងទុក្ខពីការលំបាកនានា.....ពីមួយថ្ងៃទៅមួយថ្ងៃ វានៅតែធ្វើអោយអារម្មណ៍ខ្ញុំឈឺចុកចាប់។ វាដក់ក្នុងអារម្មណ៍ខ្ញុំជារៀងរាល់ថ្ងៃ....ហេតុអីបានជាមិនមែនខ្លួនខ្ញុំជាអ្នកស្លាប់.....<br><br>**ទុត្ថា**<br>លោករិទ្ធី....បើមនុស្សម្នាក់ក្នុងចំណោមអ្នកដែលស្លាប់មានជីវិតរស់ឡើងវិញ តើលោកមានប្រតិកម្មយ៉ាង | |

| | |
|---|---|
| ម្តេចដែរ ? តើលោកនឹងធ្វើម៉េច ?<br><br>**រិទ្ធី**<br>បើអញ្ចឹងមែន ខ្ញុំពិតជាសប្បាយចិត្តណាស់ ។<br>ខ្ញុំនឹងលត់ជង្គង់សុំអោយគាត់អត់ទោសអោយខ្ញុំ។<br>ហើយនិងសុំអ្នកដែលបានស្លាប់នោះអោយបណ្តេញ<br>កម្មអាក្រក់ចេញអោយអស់ពីខ្ញុំ ។ | |

**ទុក្ខា-សុខលី ចត (និពន្ធកំណាព្យដោយលោក សំអ៊ុ អឿ "សច្ចាប្រណិធាន")**

បើខ្ញុំចោលម្សៀត កុំទុករស់ទៀត នាំធ្ងន់ផែនដី
ពន្លិចខ្ញុំចុះ អោយលិចតាមថ្ងៃ បើនៅចង្រៃ
ទឹកដីគោកធ្លក ។